**រាជបណ្ឌិត្យសភាកម្ពុជា**

# វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

## - ភាគទី១ -




អត្ថបទចងក្រងដោយៈ លោកស្រី ស៊ន ច័ន្ទអមរា
មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា

-២០១៩-

# វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

អត្ថបទចងក្រងដោយ៖ លោកស្រី ស៊ន ច័ន្ទអមរា មន្ត្រីលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១-សេចក្តីផ្តើម

សន្ធិសញ្ញាថ្ងៃទី១១ សីហា ១៨៦៣ រវាងអធិរាជបារាំង និងព្រះរាជាកម្ពុជា ដែលបានបង្កើត របបអាណាព្យាបាលនោះ ត្រូវបានចុះហត្ថលេខា នៅរាជវាំងឧដុង្គ។ មាត្រាទី១ ចែងថា «ព្រះចៅអធិរាជបារាំង ព្រមផ្តល់នូវកិច្ចការពារ ចំពោះព្រះរាជាកម្ពុជា»។ តាមមាត្រា១៦ ព្រះចៅអធិរាជបារាំង ដែលទទួលស្គាល់អធិបតេយ្យភាព នៃព្រះរាជាកម្ពុជានោះ សន្យាថានឹងថែរក្សាសណ្តាប់ធ្នាប់និងភាពសុខសាន្តនៅក្នុងប្រទេសថានឹងជួយការពារកម្ពុជាទល់នឹងរាល់ការវាយប្រហារមកពីក្រៅ ថានឹងជួយទារពន្ធពាណិជ្ជកម្ម និងថាជួយផ្តល់នូវភាពងាយស្រួលដល់កម្ពុជា ក្នុងការស្តាបនាគមនាគមន៍ រវាងកម្ពុជានិងសមុទ្រ[1]។




ផែនទីបង្ហាញអំពីដំណាក់កាលនៃការបង្កើត«សហភាពឥណ្ឌូចិន»
ដែលគ្រប់គ្រងដោយបារាំង ពីឆ្នាំ១៨៥៩ ដល់ឆ្នាំ១៨៨៧

---

[1]សន្ធិសញ្ញាដែលត្រូវបានចុះហត្ថលេខានៅឧដុង្គ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ដើម្បីកំណត់លក្ខខណ្ឌនៃរបបអាណាព្យាបាលបារាំងនៅកម្ពុជា នៅក្នុងព្រឹត្តិបត្រផ្លូវការនៃកម្ពុជាឆ្នាំ១៨៨៤, លេខ១, ខែតុលានិងវិច្ឆិកា( Traité conclu à Oudong le 11août 1863 réglant les conditions du Protectorat français au Cambodge, in Bulletin Officiel du Cambodge, Année 1884, No. 1, Octobre et Novembre )។




របបអាណាព្យាបាលបារាំង បានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ប្រជាជនកម្ពុជា ជាពិសេសក្នុងវិស័យពន្ធដារ។ ប៉ុន្តែ របបនេះក៏បាននាំមកឲ្យកម្ពុជា នូវអត្ថប្រយោជន៍នៃអរិយធម៌របស់ខ្លួនផងដែរ។

ការគង់វង្សនៃប្រជាជាតិខ្មែរ បានមកពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ រវាងបារាំង និងកម្ពុជា ជាពិសេសដោយសារកិច្ចខិតខំរបស់បារាំង លើវិស័យចំនួន៥គឺៈ ទ័ពជើងទឹក ទ័ពជើងគោក រដ្ឋបាល ការទូត និងស្រទាប់បញ្ញវន្ត។ សូមលើកយកតែតួនាទីនៃកងទ័ពជើងគោកបារាំងមកបង្ហាញដោយសង្ខេបដូចតទៅ[2]។

## ២-កិច្ចសហការបារាំង-ខ្មែរ ខាងកងទ័ពជើងគោកនៅចុងសតវត្សរ៍ទី១៩

នៅឆ្នាំ១៨៩០លោកអនុសេនីយ៍ឯកបារាំងឈ្មោះ គុយប៉េ (Cupet) ដែលអមដំណើរដោយទាហានខ្មែរម្នាក់ បានកម្ចាត់ទ័ពសៀមឱ្យដកថយពីធ្លូងលើ(ខេត្តមណ្ឌលគីរីសព្វថ្ងៃ) ទៅកាន់ស្ទឹងត្រែង នៅឆ្នាំ១៨៩៣ ទ័ពសៀមបានឆ្លងផុតទន្លេមេគង្គជាស្ថាពរ ទៅទិសខាងលិច។




សៀមបានដកទ័ពចេញពីទឹកដីខ្មែរ នៅភូមិភាគឦសាន ខាងជើង និងពាយ័ព្យ ជា៤ដំណាក់កាលគឺៈនៅឆ្នាំ១៨៩០ (ដកពីធ្លូងលើ) – នៅឆ្នាំ១៨៩៣ (ដកពីខេត្តស្ទឹងត្រែង) – នៅឆ្នាំ១៩០៤ (ដកពីខេត្តម្លូព្រៃនិងទន្លេរពៅ) – និងនៅឆ្នាំ១៩០៧ (ដកពីខេត្តបាត់ដំបង សៀមរាប និងសិរីសោភ័ណ)[3]។

## ៣-កិច្ចសហការបារាំង-ខ្មែរ ខាងកងទ័ពជើងគោកក្នុងសង្គ្រាមលោកលើកទី១

---

[2]ស៊ន សំណាង, ការយល់ឃើញ ចំពោះសម័យអាណានិគម ដោយប្រវត្តិវិទូខ្មែរម្នាក់ នៅក្នុងការផ្សាយរបស់សមាគមអ្នកប្រវត្តិសាស្ត្រ, ខែធ្នូ ឆ្នាំ២០១៣, ទំព័រ៥៦។

[3]ស៊ន សំណាង, ការវិវត្តវិស័យនយោបាយ និងរដ្ឋបាលនៅកម្ពុជានាដើមសម័យបារាំង, នៅក្នុងព្រឹត្តិបត្រប្រចាំត្រីមាស, លេខ១, ខែមករា-មីនា ឆ្នាំ២០១៨, ទំព័រ៧៥។

សាមគ្គីភាពបារាំង-ខ្មែរបែបនេះ បានបន្តជាពិសេសក្នុងអំឡុងសង្គ្រាមលោកលើកទី១។ តាមការអំពាវនាវរកអ្នកស្ម័គ្រចិត្តឱ្យទៅប្រយុទ្ធនៅប្រទេសបារាំង ព្រះរាជប្រកាសជាច្រើនត្រូវបានបិទផ្សាយនៅគ្រប់ភូមិស្រុកនៃប្រទេសកម្ពុជា។ ព្រះសង្ឃខ្មែរក៏បានរួមចំណែកផងដែរ នៅក្នុងដំណើរការជ្រើសរើសអ្នកស្ម័គ្រចិត្ត។ ចំណែកព្រះមហាក្សត្រខ្មែរក៏បានយាងទៅកាន់ខេត្តខណ្ឌនានា ក្នុងយុទ្ធនាការជ្រើសរើសអ្នកស្ម័គ្រចិត្តនេះ ដោយសន្យាថានឹងផ្តល់គ្រឿងឥស្សរិយយស ព្រមទាំងមុខងារផ្សេងៗ នៅក្នុងរដ្ឋបាល និងក្នុងរាជវាំង ចំពោះអ្នកទាំងឡាយណាដែលមានស្នាដៃលេចធ្លោ។ ៣ខែក្រោយមក មនុស្សចំនួន ១.០០៨នាក់ ត្រូវបានទទួលស្គាល់ថាមានសម្បទាគ្រប់គ្រាន់សម្រាប់បម្រើកងទ័ព។ ក្រោយសង្គ្រាមលោកលើកទី១ វិមានឧទ្ទិសចំពោះអ្នកស្លាប់សម្រាប់ប្រទេសបារាំង ត្រូវបានសម្ពោធនៅក្នុងខែកុម្ភៈ ឆ្នាំ១៩២៥ នៅទីក្រុងភ្នំពេញ[4]។

### ៣.១-ការចាប់ផ្តើមកងទ័ពនៅកម្ពុជា

«ក្រុមរក្សាស្រុក»(Garde Indigène) ពិតប្រាកដបានចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩០៤ បន្ទាប់ពី មានរាជប្រកាសចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩០៣ ដែលកំណត់អំពីរបៀបរើស«ទាហានរក្សាស្រុក»(Milicien)។ ភូមិនីមួយៗត្រូវផ្តល់ទាហានរក្សាស្រុកម្នាក់ សម្រាប់ប្រជាជន៨០នាក់ ត្រូវផ្តល់ចំនួន២នាក់ សម្រាប់ប្រជាជន ពី៨០ទៅ១៣០នាក់ ត្រូវផ្តល់៣នាក់ សម្រាប់ប្រជាជនពី១៣១ទៅ១៨០នាក់ និង ត្រូវផ្តល់ចំនួន៤នាក់ សម្រាប់ប្រជាជនពី១៨១ទៅ២៣០នាក់។ ព្រះរាជប្រកាសនោះបានកំណត់ឱ្យជ្រើសរើសឱ្យអស់ពីលទ្ធភាពនូវ មនុស្សប្រុសពោះម៉ាយនិងនៅកំលោះពីអាយុ១៨ទៅ៣៥ឆ្នាំ ប៉ុន្តែបើមិនគ្រប់ចំនួន គេត្រូវជ្រើសរើសមនុស្សប្រុស ដែលមានគ្រួសារ។ រយៈពេលបំពេញការងារគឺ២ឆ្នាំ ដោយមានលទ្ធភាពឱ្យបន្តទៅ២ឆ្នាំទៀត[5]។

ក្រុមរក្សាស្រុក មានភារកិច្ចរក្សាសណ្តាប់ធ្នាប់សង្គមនៅគ្រប់ខេត្ត។ ខេត្តនីមួយៗត្រូវជ្រើសរើស«ក្រុមពិជ័យសង្គ្រាម» មួយវរសេនាតូច ដើម្បីធ្វើអន្តរាគមន៍ក្នុងសកម្មភាពយោធាដូចជានៅក្នុងសន្តិការូបនីយកម្មខេត្តបាត់ដំបងមុនឆ្នាំ១៩១០ជាដើម[6]។ ក្រុមរក្សាស្រុកមានចំនួនចន្លោះពី១.៥០០នាក់(១៩១២-១៩១៥) និង ២.២០០-២.៤០០នាក់(១៩១៦-១៩២០)។ ចំណែកក្រុមពិជ័យសង្គ្រាមជាជនជាតិខ្មែរមានចំនួន១.៣៥០នាក់ និង រើសបន្ថែម៥០០នាក់ទៀតពីខែមករា ឆ្នាំ១៩១៦ ទៅ ខែមករា ឆ្នាំ១៩១៧ ដើម្បីចេញទៅច្បាំងនៅទ្វីបអឺរ៉ុប។

(សូមរង់ចាំអានវគ្គបន្តនៅសប្តាហ៍ក្រោយ ...)

---

[4]ស៊ិន សំណាង, ការយល់ឃើញ ចំពោះសម័យអាណានិគម ដោយប្រវត្តិវិទូខ្មែរម្នាក់, ដ.ឯ.ម.(ដូចឯកសារមុន), ទំព័រ៥៧។

[5] Alain Forest, ប្រទេសកម្ពុជានិងអាណានិគមកម្មបារាំង, ប្រវត្តិនៃអាណានិគមកម្មមួយដែលគ្មានការប៉ះទង្គិច (១៨៩៧-១៩២០), Editions L'Harmattan, ១៩៨០, ទំព័រ១៣៦។

[6] តាមព្រះរាជប្រកាសចុះថ្ងៃទី១៦កុម្ភៈ១៩១២ រយៈពេលបំពេញការងាររបស់ក្រុមរក្សាស្រុកគឺ៣ឆ្នាំ។ អ្នកចាប់ឆ្នោតបានលេខដំបូងត្រូវឱ្យចូលក្នុងក្រុមពិជ័យសង្គ្រាម ចំណែកអ្នកចាប់ឆ្នោតបានលេខក្រោយត្រូវឱ្យចូលក្នុងក្រុមរក្សាស្រុក។